**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
.............

ក្រសួងមហាផ្ទៃ
លេខ: ០៣៩.ប្រ.ក

ភ្នំពេញ. ថ្ងៃទី ១៩ ខែ ០១ ឆ្នាំ ១៩៩៨

# ប្រកាស

## ស្ដីពី

## បែបបទនៃការចុះឈ្មោះក្នុងសៀវភៅគ្រួសារ

---

## សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រម ន.ស.រ.ក.ម ០១៩៦ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ អនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៧៤ អ.ន.ក្រ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ស្ដីពីសៀវភៅគ្រួសារ
- តាមសំណើរបស់អគ្គនាយកនគរបាលជាតិ
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

ប្រការ ១ : គ្រប់គ្រួសារដែលមានសញ្ជាតិខ្មែរ មានកាតព្វកិច្ចចុះឈ្មោះសមាជិកគ្រួសារខ្លួនក្នុងសៀវភៅគ្រួសារ មួយជាកំណត់ នៅទីកន្លែងរបស់ជនបង្គោល មានឪពុក ម្ដាយ ដែលស្នាក់នៅជាអចិន្ត្រៃយ៍នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : សៀវភៅគ្រួសារនេះ ចុះបានតែប្ដី ប្រពន្ធ កូនបង្កើត ឬកូនសុំដែលមានការទទួលស្គាល់តាមផ្លូវច្បាប់ ទោះជាកូនទាំងអស់នោះ រស់នៅទីកន្លែងណាក៏ដោយ ។

ប្រការ ៣ : គណៈកម្មការត្រួតពិនិត្យ ផ្ដល់សៀវភៅគ្រួសារ ជំហានដំបូងត្រូវដំណើរការចំពោះគ្រួសារដែលមានលក្ខណៈ វិនិច្ឆ័យណាមួយដូចខាងក្រោមនេះ :

១_គ្រួសារប្រជាពលរដ្ឋខ្មែររួមមាន ជនជាតិខ្មែរ ជនជាតិភាគតិច ដែលកំពុងរស់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ។ 

២_កូនជនបរទេសដែលកើតនៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា និង បានរស់នៅជាប់ក្នុងព្រះរាជាណាចក្រកម្ពុជារហូតដល់មានប្តី ឬ ប្រពន្ធ ។

៣_កូនដែលកើតពីឪពុក ឬម្តាយ មានសញ្ជាតិខ្មែរ និង រស់នៅជាប់ក្នុងព្រះរាជាណាចក្រកម្ពុជា រហូតដល់មានប្តីឬ ប្រពន្ធ ។

៤_គ្រួសារដែលមានប្តីឬប្រពន្ធ ជាជនបរទេស ហើយបានរស់នៅជាប់ក្នុងព្រះរាជាណាចក្រកម្ពុជា យ៉ាងតិច ៣ឆ្នាំ ក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍ និង មានព្រះរាជក្រឹត្យសំរេចផ្តល់សញ្ជាតិខ្មែរ ។

៥_ជនបរទេស ដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមការកំណត់ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ និង បានអនុញ្ញាតអោយចូលសញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ឬ ការទាមទារសញ្ជាតិខ្មែរ តាមការកំណត់នៃច្បាប់ស្តីពីសញ្ជាតិ ។

ប្រការ ៤ : ការចុះឈ្មោះក្នុងសៀវភៅគ្រួសារ ការគ្រប់គ្រង ការប្រែប្រួល និង ការកែតម្រូវផ្សេងៗ ជាសមត្ថកិច្ចរបស់ស្នងការនគរបាលខេត្ត ក្រុង ។

ប្រការ ៥ : ជនដែលត្រូវបានលុបឈ្មោះចេញពីសៀវភៅគ្រួសារ គឺជនដែលបានទទួលសាលក្រមស្ថាពរអោយដាច់សមត្ថសង្វាស ។

ប្រការ ៦ : ជនណា ដែលបានអនុវត្តផ្ទុយពីប្រការនៃប្រកាសនេះត្រូវទទួលទោសតាមច្បាប់ ។

ប្រការ ៧ : អគ្គនាយកដ្ឋាននគរបាលជាតិ មានភារកិច្ចកំណត់ អំពីបែបបទនៃការចុះឈ្មោះ និង គ្រប់គ្រងសៀវភៅគ្រួសារនេះ ។

អភិបាលខេត្ត ក្រុង មានភារកិច្ចចាត់តាំង ណែនាំអនុវត្តការងារនេះអោយមានប្រសិទ្ធិភាព ។

ប្រការ ៨ : ប្រកាសលេខ ៥៦៦ប្រក ចុះថ្ងៃទី ២១ ខែ ១១ ឆ្នាំ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៩ : នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកនគរបាលជាតិ អគ្គាធិការកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល អភិបាលខេត្ត ក្រុង និង គ្រប់អង្គភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស ខេង

សរ ខេង

ចំលងជូន :

_ទីស្តីការគណៈរដ្ឋមន្ត្រី

_ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

_គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ

_ដូចប្រការ ៩

_ឯកសារ

_កាលប្បវត្តិ